**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

**តុលាការព្រហ្មទណ្ឌ**

**សំណុំរឿងព្រហ្មទណ្ឌលេខ ១៨៧៨ អ.ក**

ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣

**សំណុំរឿងស៊ើបសួរលេខ ១១៩៦ ស.ស**

ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣

**សំណុំរឿងជំនុំជម្រះលេខ ៥៤៥ ជ.រ**

ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

**សាលក្រមព្រហ្មទណ្ឌលេខ ០៣៧ /ក**

ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្តាល

កាលបរិច្ឆេទនៃសវនាការ ៖ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤។

សាលសវនាការ និងពេលវេលា ៖ សាល ៤ ម៉ោង ១០ ព្រឹក។

កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤។

សាលសវនាការ និងពេលវេលា ៖ សាល ៤ ម៉ោង ១១ ព្រឹក។

ក្រោមសមាសភាពជំនុំជម្រះ រួមមាន៖

### ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល និងជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល និងជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល និងជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**ក. អំពីអត្តសញ្ញាណជនជាប់ចោទ**

១. ឈ្មោះ [redacted] **ម៉ារ៉ុង** ភេទប្រុស អាយុ ៣១ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ កសិករ។

ទីកន្លែងកំណើតនៅភូមិកោះ[redacted] ខេត្តកណ្តាល។

ទីលំនៅភូមិកោះ[redacted] ខេត្តកណ្តាល។

ឪពុកឈ្មោះ [redacted] វ៉េន (រ) ម្តាយឈ្មោះ [redacted] ស៊ីណាត (រ) នៅលីវ

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ គ្មាន។ (ក្នុងឃុំ)

កាលបរិច្ឆេទនៃការឃាត់ខ្លួន ៖ ថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការឃុំខ្លួនជាបណ្តោះអាសន្ន៖ ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤។



Scanned with CamScanner

កាលបរិច្ឆេទនៃការរក្សាទុកក្នុងការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤។

ជាប់ចោទពីបទ **ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្ដាល កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ **ក្រុមមេធាវីនីតិ** អាសយដ្ឋានស្ថិតអគារលេខAP១៤៤៣ ផ្លូវអភិវឌ្ឍន៍ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ **ក្រុមមេធាវី សុធាផល សំណាង សុភី និងសហការី** អាសយដ្ឋាននៅមជ្ឈមណ្ឌលកោះពេជ្រ អគារជីអាយអេ ជាន់ទី២៥ បន្ទប់លេខ ១៣-១៥ វិថីសុភមង្គល សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**២.** ឈ្មោះ [redacted] **ម៉ារ៉ុន** ហៅ **ញ៉ាញ់** ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ នេសាទ។

ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្ដាល។ (គេចខ្លួន)

ទីលំនៅភូមិកោះចំរើន ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted] រ៉េន (រ) ម្ដាយឈ្មោះ [redacted] ស៊ីណាត (រ) ប្រពន្ធឈ្មោះ [redacted] ចិន្ដា មានកូន ៣ នាក់។

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅខេត្តព្រៃវែង កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**សំណុំរឿងព្រហ្មទណ្ឌនេះបញ្ជូនមកជំនុំជម្រះតាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៣២ ដកស ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល ដែលមាន៖**

**អង្គហេតុដែលប្ដឹងមកតុលាការ**

កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ កម្លាំងនគរបាលជំនាញប្រឆាំងបទល្មើសគ្រឿងញៀននៃអធិការដ្ឋាននគរបាលស្រុកលើកដែក បានទទួលសេចក្ដីរាយការណ៍ពីប្រជាពលរដ្ឋក្នុងមូលដ្ឋានថា បានឃើញស្ត្រីម្នាក់ឈ្មោះ [redacted] **ចិន្ដា** ភេទស្រី អាយុ ២១ ឆ្នាំ ជាប្អូនថ្លៃរបស់ឈ្មោះ [redacted] **ម៉ារ៉ុង** ភេទប្រុស អាយុ ៣១ ឆ្នាំ ជាមុខសញ្ញាណជួញដូរគ្រឿងញៀន មកទទួលអីវ៉ាន់ពីក្រុមហ៊ុនវិរៈប៊ុនថាំ ដោយសង្ស័យអីវ៉ាន់នោះជាគ្រឿងញៀន។ លុះដល់ម៉ោង ១៥ និង ១០ នាទី ថ្ងៃដដែល កម្លាំងជំនាញបានឃ្លាំមើលនៅចំណុចក្រុមហ៊ុនវិរៈប៊ុនថាំ ក៏បានឃើញឈ្មោះ [redacted] **ចិន្ដា** មកទទួលកញ្ចប់អីវ៉ាន់ពីក្រុមហ៊ុនវិរៈប៊ុនថាំ ដោយនៅលើកញ្ចប់នោះមានសរសេរលេខអ្នកផ្ញើលេខ ០៨៦៧២៩៧៩៩ និងលេខអ្នកទទួល ០៧១៣០៤៨៧៥២ ពេលទទួលអីវ៉ាន់បានហើយ សមត្ថកិច្ចក៏បានឃាត់ដំណើរឈ្មោះ [redacted] **ចិន្ដា** និងឆែកឆេរមើលកញ្ចប់អីវ៉ាន់នោះរកឃើញវត្ថុតាងម្សៅក្រាម សង្ស័យជាសារធាតុញៀនចំនួន ១ កញ្ចប់មធ្យម ទម្ងន់ ២៤,៤៨ ក្រាម។ ក្រោយសមត្ថកិច្ចសួរនាំ ឈ្មោះ [redacted] **ចិន្ដា** រួចមកដឹង

ថា ឈ្មោះ [redacted] **ម៉ារ៉ុង** ជាម្ចាស់គ្រឿងញៀនខាងលើ ភ្លាមនោះសមត្ថកិច្ចបានបន្តទៅចាប់ខ្លួនឈ្មោះ [redacted] **ម៉ារ៉ុង**។ ក្នុងប្រតិបត្តិការនេះ សមត្ថកិច្ចបានចាប់យកវត្ថុតាងរួមមាន ម្សៅក្រាមសង្ស័យជាសារធាតុញៀនចំនួន ១ កញ្ចប់ខាងលើ ម៉ូតូចំនួន ១ គ្រឿង ទូរស័ព្ទចំនួន ២ គ្រឿង ខោជើងវែងមួយ និងថង់វេចខ្ចប់របស់ក្រុមហ៊ុនវីរៈប៊ុនថាំ រួចនាំខ្លួនឈ្មោះ [redacted] **ម៉ារ៉ុង** និងឈ្មោះ [redacted] **ចិន្តា** យកទៅសាកសួរ និងធ្វើតេស្តទឹកនោមជាលទ្ធផលឈ្មោះ [redacted] **ម៉ារ៉ុង** វិជ្ជមានសារធាតុញៀន រួចបានកសាងសំណុំរឿងបញ្ជូនឈ្មោះ [redacted] **ម៉ារ៉ុង** និងវត្ថុចាប់យកខាងលើមកអយ្យការអមសាលាដំបូងខេត្តកណ្តាល ដើម្បីចាត់ការតាមច្បាប់។ ចំណែកឈ្មោះ [redacted] **ចិន្តា** ក្រោយពីសមត្ថកិច្ចសាកសួររួច ក៏បានអនុញ្ញាតឱ្យត្រឡប់ចូលទៅរស់នៅក្នុងមូលដ្ឋានវិញ។ នៅចំពោះមុខនគរបាលយុត្តិធម៌ និងនៅអយ្យការ ឈ្មោះ [redacted] **ម៉ារ៉ុង** បានសារភាពថា រូបគេបានប្រើប្រាស់លេខទូរស័ព្ទ ០៧១ ៣០៤៨៧៥២ ទំនាក់ទំនងទៅឈ្មោះ [redacted] **ម៉ារ៉ុន** ភេទប្រុស អាយុ ២៥ ឆ្នាំ ជាប្អូនបង្កើត និងឈ្មោះ **ណាន់** ភេទប្រុស ដើម្បីទិញគ្រឿងញៀន ក្នុងតម្លៃ ១ លានរៀល ដើម្បីយកមកលក់បន្ត ហើយឈ្មោះ [redacted] **ម៉ារ៉ុន** និងឈ្មោះ **ណាន់** ក៏ឱ្យបក្ខពួក (មិនស្គាល់អត្តសញ្ញាណ) ជាអ្នកលក់គ្រឿងញៀន ផ្ញើគ្រឿងញៀន និងទទួលប្រាក់តាមលេខទូរស័ព្ទ ០៨៦ ៧២៩៧៩៩ តាមក្រុមហ៊ុន **WING (វីង)**។

## អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី

### ក. អំពីកិច្ចពិភាក្សាដេញដោលមុនពេលអង្គសេចក្តី

អំពីវិវាទកម្មស្តីពីនិយតភាពនៃការរកោះហៅ តាមមាត្រា ៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ គ្មាន។

អំពីអញ្ញត្រកម្ម តាមមាត្រា ៣៤២ ដល់មាត្រា ៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ គ្មាន។

### ខ. អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី

#### ១. ការសួរចម្លើយជនជាប់ចោទ

**១.១.** ឈ្មោះ [redacted] **ម៉ារ៉ុង** ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ មូលហេតុដែលសមត្ថកិច្ចនាំខ្លួនមកទីនេះគឺដោយសារខ្លួនបានទិញថ្នាំញៀនយកមករំលែកលក់បន្ត។ ខ្លួនទិញថ្នាំញៀនមកលក់បន្តដោយសារបានប្រាក់ចំណេញ និងថ្នាំញៀនសម្រាប់ប្រើប្រាស់។ ថ្នាំញៀននោះគឺប្រភេទម៉ាទឹកកក។ ខ្លួនបានទាក់ទងទិញតាមទូរស័ព្ទក្នុងតម្លៃ ១,000,000 (មួយលាន) រៀល។ ខ្លួនបានតេទូរស័ព្ទទំនាក់ទំនងឈ្មោះ **ណាន់** ដែលកំពុងជាប់ពន្ធនាគារខេត្តព្រៃវែង ហើយឈ្មោះ **ណាន់** បានប្រាប់ថាចាំជួយទាក់ទងអ្នកលក់ថ្នាំញៀនអោយ ហើយបានឱ្យខ្លួនវេលុយអោយតាមលេខទូរស័ព្ទ ០៨៦ ៧២៩៧៩៩ ចំណែកលេខទូរស័ព្ទដែលខ្លួនប្រើប្រាស់ទាក់ទងជាមួយគេគឺលេខ ០៧១ ៣០៤៤៨៧៥២ ចំណែកឈ្មោះ **ណាន់** គឺពុំមានលេខទូរស័ព្ទទំនាក់ទំនងច្បាស់លាស់ឡើយពេលគាត់តេទូរស័ព្ទមកខ្លួនគឺប្រើប្រាស់លេខទូរស័ព្ទផ្សេងៗគ្នា ប៉ុន្តែមានលេខទូរស័ព្ទមួយខ្សែរ គឺ ០៦០ ២២៤១០៣ ដោយប្រាប់គេថាសុំជួបឈ្មោះ **ណាន់** រីចង់ជួបអ្នកផ្សេងទើបគេប្រាប់ឱ្យតេទូរស័ព្ទទាក់ទងមកវិញ ចំណែកអ្នកលក់ថ្នាំញៀនឱ្យមកខ្លួនគឺមិនបានដឹងច្បាស់លាស់ថាជានណារឡើយ។ ខ្លួនស្គាល់ឈ្មោះ **ណាន់** មិនច្បាស់លាស់ទេ ហើយក៏មិនដែលឃើញមុខគ្នាដែរ ហើយក៏មិនដែលមានទំនាក់ទំនងគ្នាពីមុនមកដែរ ខ្លួនស្គាល់ឈ្មោះ **ណាន់** តាមរយៈឈ្មោះ [redacted] **ម៉ារ៉ុន ហៅ ញ៉ាញ់** ត្រូវជាប្អូនបង្កើតរបស់ខ្លួនដែលកំពុងជាប់ពន្ធនាគារខេត្តព្រៃវែង ពាក់

ព័ន្ធបទល្មើសគ្រឿងញៀន។ បើតាមខ្លួនបានសួរនាំឈ្មោះ [redacted] **ម៉ារ៉ុន ហៅ ញ៉ាញ់** គឺគេស្គាល់ឈ្មោះ **ណាន់** នៅក្នុងពន្ធនាគារខេត្តព្រៃវែងជាមួយគ្នា។ នៅពេលដែលឈ្មោះ [redacted] **ម៉ារ៉ុន ហៅ ញ៉ាញ់** ជាប់ពន្ធនាគារគេបានតេទូរស័ព្ទប្រាប់ខ្លួនថាបើចង់មានលុយចាយ មានថ្នាំញៀនជក់ចាំតេទាក់ទងឱ្យទិញយកទៅលក់ទៅ ក្រោយមកបានប្រហែល ០៤ ទៅ ០៥ថ្ងៃ ខ្លួនក៏បានសម្រេចចិត្ត ធ្វើតាមគេនិយាយប្រាប់បន្ទាប់មកគេបានទាក់ទងទៅឈ្មោះ **ណាន់** រួច ក៏ឱ្យឈ្មោះ **ណាន់** តេទូរស័ព្ទទាក់ទងមកខ្លួនដើម្បីនិយាយគ្នារឿងទិញថ្នាំញៀន។ ខ្លួនសូមធ្វើការរៀបរាប់នូវហេតុការណ៍ដែលបានកើតឡើងតាមលំដាប់លំដោយដូចខាងក្រោម៖ បន្ទាប់ពីខ្លួនបានធ្វើការទាក់ទងជាមួយប្អូនប្រុសបង្កើតរបស់ខ្លួនឈ្មោះ [redacted] **ម៉ារ៉ុន ហៅ ញ៉ាញ់** និងឈ្មោះ **ណាន់** រួចហើយតាមរយៈទូរស័ព្ទដៃដើម្បីទិញថ្នាំញៀនយកមកលក់បន្ត ដោយខ្លួនបានទិញថ្នាំញៀនគិតជាលុយ ១,០០០,០០០៛ និងបានធ្វើការវេលុយតាមក្រុមហ៊ុន (វីង) ទៅអ្នកលក់ថ្នាំញៀនតាមរយៈលេខទូរស័ព្ទ ០៨៦ ៧២៩៧៩៩ ចំនួន ៦០០,០០០៛ ដោយនៅជំពាក់គេចំនួន ៤០០,០០០៛ ដោយសន្យាជាមួយគេថាពេលលក់ថ្នាំញៀនបានលុយទើបផ្ញើរអោយបង្គ្រប់ចំនួន ចំណែកថ្នាំញៀនឈ្មោះ **ណាន់** បានតេទូរស័ព្ទប្រាប់ខ្លួនថាអីវ៉ាន់នោះគេមិនយកទៅអោយទេ គេផ្ញើរតាមឡានទៅអោយលុះរយៈពេល ០២ថ្ងៃមិនទាន់បានដំណឹងពីអីវ៉ាន់ នៅព្រឹកថ្ងៃទី០៣ ខែតុលា ឆ្នាំ ២០២៣ ខ្លួនបានឃើញប្អូនស្រីថ្លៃរបស់ខ្លួនឈ្មោះ **ងា** មកលេងផ្ទះម៉ែខ្លួនក៏ល្មៀតពឹងគាត់ឱ្យទៅសួររកមើលអីវ៉ាន់នៅក្រុមហ៊ុនវិរៈប៊ុនថាំ ថាក្រែងដឹងតែខ្លួនមិនស្គាល់ទីតាំងក្រុមហ៊ុននោះនៅកន្លែងណាទេ ចំណែកប្អូនថ្លៃខ្លួនគាត់ប្រាប់ថាគាត់ស្គាល់ព្រោះគាត់ធ្លាប់ទិញឡេលាបខ្លួនតាមអនឡាញ និងបានទៅយកនៅទីនោះបន្ទាប់មកគាត់ក៏ជិះម៉ូតូទៅបានប្រហែលជិត ០២ម៉ោង គាត់ក៏ត្រឡប់មកវិញ ហើយប្រាប់ថាអីវ៉ាន់មិនទាន់បានទេ ដោយខាងក្រុមហ៊ុនប្រាប់ថាបើមានអីវ៉ាន់ចូលចាំគេតេទូរស័ព្ទប្រាប់ (នៅពេលដែលខ្លួនប្រាប់ប្អូនថ្លៃខ្លួនឱ្យទៅជួយរកមើលអីវ៉ាន់ខ្លួនមិនបានប្រាប់គាត់ថាអីវ៉ាន់នោះ ជាថ្នាំញៀនទេ គឺប្រាប់គាត់ថាអីវ៉ាន់នោះគឺ ខោទិញគេតាមអនឡាញ) បន្ទាប់មកគាត់ក៏បានត្រឡប់ទៅផ្ទះរបស់គាត់វិញនៅភូមិកំពង់ចម្លង ឃុំព្រែកទន្លាប់ ស្រុកលើកដែក។ លុះដល់ម៉ោង ២ ជាងរសៀលមានទូរស័ព្ទតេមកប្រាប់ថាអីវ៉ាន់របស់ខ្លួនមកដល់ហើយអោយទៅយកនៅក្រុមហ៊ុនវិរៈប៊ុនថាំ ដោយខ្លួនមិនស្គាល់ទីតាំងច្បាស់ខ្លួនក៏ខ្ចីម៉ូតូបងថ្លៃរបស់ខ្លួនជិះទៅផ្ទះប្អូនថ្លៃស្រីរបស់ខ្លួនឈ្មោះ **ងា** ដើម្បីពឹងគាត់អោយជួយទៅយកអីវ៉ាន់ហើយបានអោយទូរស័ព្ទដែលខ្លួនបានដាក់លេខទំនាក់ទំនងទៅគាត់ បន្ទាប់មកគាត់ក៏បានជិះម៉ូតូដែលខ្លួនជិះមកផ្ទះចេញទៅបាត់ទៅបានមួយសន្ទុះឃើញប៉ូលីសជិះម៉ូតូមកឃាត់ខ្លួនតែម្តង។ ឈ្មោះ **ងា** ពិតជាមិនមានការពាក់ព័ន្ធ នឹងគ្រឿងញៀននេះទេពីព្រោះខ្លួនបានប្រើគាត់និងគុហក់គាត់ថាឱ្យជួយទៅយកខោដែលខ្លួនទិញតាមអនឡានហើយខ្លួនមិនស្គាល់កន្លែងទីតាំងក្រុមហ៊ុនវិរៈប៊ុនថាំ តែគាត់ស្គាល់ទើបខ្លួនពឹងគាត់។

**១.២.** ឈ្មោះ [redacted] **ម៉ារ៉ុង** ចំពោះមុខតំណាងអយ្យការ៖ ខ្លួនសូមរក្សាចម្លើយដូចក្នុងកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២៣ ទុកជាបានការដដែល។ សមត្ថកិច្ចឃាត់ខ្លួនមកព្រោះខ្លួនជាអ្នកលក់ថ្នាំញៀន។ ថ្នាំញៀនដែលសមត្ថកិច្ចដកហូត គឺខ្លួនបានទិញនៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ ទិញពីឈ្មោះ **ណាន់** មិនស្គាល់ត្រកូលទេ (ខ្លួនពុំដែលស្គាល់គាត់ពីមុន និងពុំដែលធ្លាប់ឃើញមុខគាត់

ទេ ពីព្រោះខ្លួនបានស្គាល់ទាក់ទងទិញថ្នាំញៀនតាមរយៈលេខទូរស័ព្ទ ដោយប្អូនបង្កើតខ្លួនឈ្មោះ [redacted] **ម៉ារ៉ុន ហៅ ញ៉ាញ់** ភេទប្រុស អាយុ ២៥ ឆ្នាំ គាត់ជាប់ពន្ធនាគារខេត្តព្រៃវែង) បានឱ្យខ្លួនទាក់ទងតាមលេខទូរស័ព្ទ ដើម្បីទាក់ទងទិញថ្នាំញៀន ដោយខ្លួនទិញថ្នាំញៀនចំនួន ១,000,000៛ ពីឈ្មោះ **ណាន់** ដោយគេបានផ្ញើគ្រឿងញៀនតាមរយៈក្រុមហ៊ុនវិរៈប៊ុនថាំ ហើយខ្លួនបានវេលុយឱ្យទៅគេវិញតាមវីង។ ឈ្មោះ **ណាន់** កំពុងជាប់ពន្ធនាគារខេត្តព្រៃវែង ហើយខ្លួនស្គាល់ឈ្មោះ **ណាន់** តាមរយៈឈ្មោះ [redacted] **ម៉ារ៉ុន ហៅ ញ៉ាញ់** ជាប្អូនរបស់ខ្លួនដែលកំពុងជាប់ពន្ធនាគារខេត្តព្រៃវែងដែរ បានប្រាប់ខ្លួនឱ្យរកស៊ីគ្រឿងញៀន។ ឈ្មោះ **ណាន់** ជាអ្នកទំនាក់ទំនងមកកាន់លេខទូរស័ព្ទខ្លួនផ្ទាល់ ខ្លួនពុំចាំលេខទូរស័ព្ទរបស់ខ្លួនទេចាំតែកន្ទុយ ៨២ ទំនាក់ទំនងលក់គ្រឿងញៀនឱ្យខ្លួន ដោយទំនាក់ទំនងមកខ្លួនតាមលេខ ០៨៦៧២៩៧៩៩។ ឈ្មោះ **ណាន់** បានប្រាប់ខ្លួនថាគ្រឿងញៀនផ្ញើតាមក្រុមហ៊ុនវិរៈប៊ុនថាំ ដាក់ក្នុងខោ ហើយពេលដែលគ្រឿងញៀនមកដល់ ខាងបុគ្គលិកក្រុមហ៊ុនវិរៈប៊ុនថាំបានតេមកខ្លួនលេខ ០៧១៣០៤៨៧៥២ ដែលដាក់លើកញ្ចប់អីវ៉ាន់ ជាលេខរបស់ម្ដាយខ្លួន ហើយនៅថ្ងៃនោះខ្លួនបានខ្ចីទូរស័ព្ទម្ដាយរបស់ខ្លួនតេ។ បានជាខ្លួនខ្ចីទូរស័ព្ទម្ដាយខ្លួនយកទៅប្រើព្រោះទូរស័ព្ទខ្លួន តេនិយាយស្ដាប់គ្នាមិនបានឮដាច់ៗ។ ថ្នាំញៀនខាងលើសមត្ថកិច្ចដកហូតបានពេលដែលខ្លួនពឹងឱ្យប្អូនឈ្មោះ [redacted] **ចិន្តា** ភេទស្រី អាយុ ២៤ ឆ្នាំ ជាប្អូនថ្លៃរបស់ខ្លួនដោយខ្លួនប្រាប់គាត់ឱ្យជួយទៅយកខោពីក្រុមហ៊ុនវិរៈប៊ុនថាំ ពីព្រោះខ្លួនពុំស្គាល់ក្រុមហ៊ុនទេ ណាមួយគាត់ធ្លាប់ទិញអីវ៉ាន់ដែលគេផ្ញើតាមក្រុមហ៊ុនវិរៈប៊ុនថាំ ហើយខ្លួនបានឱ្យទូរស័ព្ទដែលខ្លួនខ្ចីម្ដាយលេខ ០៧១៣០៤៨៧៥២ ឱ្យទៅប្អូនថ្លៃ ដើម្បីទំនាក់ទំនងយកអីវ៉ាន់ ពេលដែលប្អូនថ្លៃខ្លួនយកអីវ៉ាន់មានខោ និងថ្នាំញៀននៅខាងក្នុងខោបានហើយ (គាត់មិនដឹងថាមានថ្នាំញៀននៅខាងក្នុងនោះទេ) គាត់បានចេញមកវិញ ស្រាប់តែសមត្ថកិច្ចឃាត់ខ្លួនគាត់សួរនាំ និងដកហូតខោ និងថ្នាំញៀនខាងលើនោះ ហើយសមត្ថកិច្ចក៏បានមកឃាត់ខ្លួននៅតាមផ្លូវភូមិព្រែកទម្លាប់ ក្នុងស្រុកលើកដែក ដកហូតម៉ូតូម៉ាកសង់សេរីឆ្នាំ ២០២១ ជារបស់ឪពុកខ្លួន ដកហូតទូរស័ព្ទបានចំនួន ២ គ្រឿង។ សុំបញ្ជាក់ថាប្អូនថ្លៃខ្លួនឈ្មោះ [redacted] **ចិន្តា** ពុំមានទូរស័ព្ទប្រើប្រាស់នោះទេ។ ពីមុនមកខ្លួនធ្លាប់ទិញអីវ៉ាន់តាម Online (ខោ) ចំនួន ១ ដងដែរ នៅអំឡុងឆ្នាំ ២០២២ ដោយអ្នកលក់នៅភ្នំពេញ ហើយគេផ្ញើតាមរយៈក្រុមហ៊ុនវិរៈប៊ុនថាំ នៅម្តុំគល់ស្ពានអ្នកលឿង។ ថ្នាំញៀនខាងលើខ្លួនពុំទាន់បានលក់ដូរនោះទេ ខ្លួនទិញមកបម្រុងយកមកចែករំលែកលក់ និងទុកប្រើប្រាស់ផងដែរ ដោយលុយដែលខ្លួនយកទៅទិញថ្នាំញៀន គឺខ្លួនធ្វើស្រែចំការ និងដាំបន្លែសន្សំលុយយកទៅទិញគ្រឿងញៀន។ ក្រៅពីឈ្មោះ **ណាន់** ខាងលើខ្លួនធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ **ធូ** ភេទប្រុស អាយុប្រហែលជា ២៤ ឆ្នាំ នៅភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្ដាល(តែវាត្រូវបានសមត្ថកិច្ចឃាត់ខ្លួនយកមកតុលាការកាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣) ទិញម្ដង ១០ ដុល្លារអាមេរិក យកមកប្រើប្រាស់។ ខ្លួនទើបតែទិញថ្នាំញៀនពីឈ្មោះ **ណាន់** ខាងលើជាលើកទី១ទេ ខ្លួនទិញបំណងយកមកលក់បន្តដើម្បីចំណេញ តែខ្លួនពុំធ្លាប់លក់គ្រឿងញៀនពីមុនទេ។ ខ្លួនសុំសំណូមពរឱ្យតុលាការជួយបន្ធូរបន្ថយទោសខ្លួនផង។

១.៣. ឈ្មោះ [redacted] **ម៉ារ៉ុង** ចំពោះមុខចៅក្រមស៊ើបសួរ៖ ខ្លួនសូមរក្សាចម្លើយដែលឆ្លើយនៅចំពោះមុខតំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាលកាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ទុកជាបានការដដែល។

កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ នៅវេលាម៉ោង ៤ រសៀល នៅពេលនោះខ្លួនបានឱ្យប្អូនស្រីថ្លៃរបស់ខ្លួនឈ្មោះ [redacted] ចិន្តា ភេទស្រី អាយុ ២៥ ឆ្នាំ ទៅយកអីវ៉ាន់ពីក្រុមហ៊ុនវីរៈប៊ុនថាំ ដោយផ្ញើពីរង្វង់មូលអ្នកលឿងចេញទៅព្រែកទន្លាប់។ បន្ទាប់មកប្អូនស្រីថ្លៃខ្លួនក៏បានទៅយកថ្នាំញៀន ពីក្រុមហ៊ុនវីរៈប៊ុនថាំ គឺខោកាបូយ ដែលខ្លួនបានទិញពីឈ្មោះ **ណាន់** ភេទប្រុស (បច្ចុប្បន្នកំពុងជាប់ពន្ធនាគារខេត្តព្រៃវែង) ដោយពេលទិញខោកាបូយនោះ គឺឈ្មោះ **ណាន់** បានលាក់ទុកថ្នាំញៀននៅក្នុងខោខាប៊ូយ ហើយបន្ទាប់មកខ្លួនក៏បានឱ្យប្អូនស្រីថ្លៃរបស់ខ្លួនឈ្មោះ [redacted] **ចិន្តា** ទៅយកថ្នាំញៀននៅក្រុមហ៊ុនវីរៈប៊ុនថាំ។ បន្ទាប់ពីប្អូនស្រីថ្លៃខ្លួនទទួលបានកញ្ចប់អីវ៉ាន់ ដែលឈ្មោះ **ណាន់** បានផ្ញើនោះភ្លាម ស្រាប់តែមានកម្លាំងសមត្ថកិច្ចនៃអធិការដ្ឋាននគរបាលស្រុកលើកដែក បានធ្វើការឃាត់ម៉ូតូរបស់ប្អូនស្រីថ្លៃខ្លួន និងឆែកឆេរនៅលើអីវ៉ាន់ដែលផ្ញើតាមរយៈក្រុមហ៊ុនវីរៈប៊ុនថាំនោះ ឃើញថាកញ្ចប់ដែលផ្ញើនោះគឺជាអីវ៉ាន់ថ្នាំញៀន បន្ទាប់មកសមត្ថកិច្ចក៏បានយកប្អូនស្រីរបស់ខ្លួនទៅសួរនាំនៅអធិការដ្ឋាននគរបាលស្រុកលើកដែក ពេលនោះប្អូនស្រីថ្លៃខ្លួនបានឆ្លើយសារភាពថា ថ្នាំញៀននេះគឺជារបស់បងប្រុសខ្លួនឈ្មោះ [redacted] **ម៉ារ៉ុង** ដែលបានឱ្យខ្លួនមកយកនៅក្រុមហ៊ុនវីរៈប៊ុនថាំ ដើម្បីយកទៅឱ្យគាត់។ បន្ទាប់មកសមត្ថកិច្ចនៃអធិការដ្ឋាននគរបាលស្រុកលើកដែក បានធ្វើការឃាត់ខ្លួនបញ្ជូនមកអធិការដ្ឋាននគរបាលស្រុកលើកដែកដើម្បីធ្វើការសាកសួរបន្ត ពេលនោះខ្លួនបានឆ្លើយសារភាពថា ថ្នាំញៀន ដែលខ្លួនបានផ្ញើឱ្យប្អូនស្រីថ្លៃខ្លួនទៅយកនេះគឺជារបស់ខ្លួនដែលបានទិញពីឈ្មោះ **ណាន់** (បច្ចុប្បន្នកំពុងជាប់ពន្ធនាគារខេត្តព្រៃវែង) ដោយថ្នាំញៀននេះខ្លួនបានទិញក្នុងតម្លៃ ៦០០,០០០(ហុកសិបម៉ឺន)រៀល យកមកទុកសម្រាប់ជក់ ដោយខ្លួនជក់ថ្នាំញៀនក្នុងមួយថ្ងៃ ៣ ទៅ ៤ ដង។ ខ្លួនសូមបញ្ជាក់ថា ចំណែកឈ្មោះ [redacted] **ម៉ារ៉ុន** ភេទប្រុស អាយុ ២៥ ឆ្នាំ (បច្ចុប្បន្នកំពុងជាប់ពន្ធនាគារខេត្តព្រៃវែង) គឺជាប្អូនប្រុសបង្កើតរបស់ខ្លួនដែលបានតេទូរស័ព្ទមកខ្លួន ឱ្យខ្លួនមានទំនាក់ទំនងជាមួយឈ្មោះ **ណាន់** ដែលបច្ចុប្បន្នកំពុងជាប់ពន្ធនាគារខេត្តព្រៃវែង ក្នុងការទិញលក់ថ្នាំញៀន។ ខ្លួនធ្លាប់បានទិញថ្នាំញៀនជាច្រើនដង ពីឈ្មោះ **ធូ** ភេទប្រុស ២៤ ឆ្នាំ នៅអំពិលទឹក ដោយទិញថ្នាំញៀនម្តងមួយកញ្ចប់តម្លៃ ៤០,០០០(បួនម៉ឺន)រៀល។ នៅពេលសមត្ថកិច្ចឃាត់ខ្លួន ដកហូតបានថ្នាំញៀន ១ កញ្ចប់ និងទូរស័ព្ទ ២ គ្រឿង។ ខ្លួនសូមបញ្ជាក់ថាឈ្មោះ [redacted] **ចិន្តា** ភេទស្រី អាយុ ២៥ ឆ្នាំ ដែលត្រូវជាប្អូនថ្លៃរបស់ខ្លួនគឺមិនជាប់ពាក់ព័ន្ធជាមួយរឿងនេះទេ។ ខ្លួនសូមសំណូមពរដល់តុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ព្រោះខ្លួនបានដឹងពីកំហុសហើយ។

**១.៤.** ឈ្មោះ [redacted] **ម៉ារ៉ុង** ក្នុងកិច្ចពិភាក្សាដេញដោល៖ នៅថ្ងៃកើតហេតុខ្លួនចេញពីផ្ទះ ដើម្បីទៅយកថ្នាំញៀននៅវីរៈប៊ុនថាំ ដោយឈ្មោះ ណាន់ ផ្ញើមក។ ថ្នាំញៀនដែលឈ្មោះ ណាន់ ផ្ញើមកតម្លៃ ២០០.០០០ រៀល។ ខ្លួនដឹងថាឈ្មោះ ណាន់ ប្រាប់ខ្លួនថាផ្ញើថ្នាំញៀនមក។ ពេលខ្លួនទៅយកឥវ៉ាន់ជាថ្នាំញៀន ស្រាប់តែសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួន និងឈ្មោះ ណាន់ គឺទាក់ទងតាមទូរស័ព្ទ ប្រាប់ថាផ្ញើតាមវីរៈប៊ុនថាំ។ ឈ្មោះ [redacted] ម៉ារ៉ុន ជាអ្នកឱ្យលេខមកខ្លួន គឺលេខឈ្មោះ ណាន់។ ឈ្មោះ [redacted] ម៉ារ៉ុន ជាអ្នកឱ្យលេខមកខ្លួនទូរស័ព្ទចេញពីពន្ធនាគារខេត្តព្រៃវែង ឱ្យខ្លួនទាក់ទងទៅឈ្មោះ ណាន់ ដើម្បីទិញថ្នាំញៀន។ ខ្លួនមិនដែលរកស៊ីថ្នាំញៀនទេ ទើបតែលក់លើកទី១ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនរយៈពេល ៥ ឆ្នាំមកហើយ។ ថ្នាំញៀនដែលខ្លួនទិញតាមវីរៈប៊ុនថាំ គឺខ្លួន



Scanned with CamScanner

ទិញមកប្រើប្រាស់មិនមែនទិញយកមកលក់នោះទេ។ ខ្លួនប្រកបមុខរបរធ្វើស្រែចម្ការ។ ថ្នាំញៀននោះខ្លួនទិញមកដើម្បីជួញដូរ។ ឈ្មោះ [redacted] ម៉ារ៉ន កំពុងជាប់ពន្ធនាគារនៅខេត្តព្រៃវែង។ ឈ្មោះ [redacted] ម៉ារ៉ន ឱ្យខ្លួនទាក់ទងទៅដើម្បីទិញថ្នាំញៀន។ ឈ្មោះ [redacted] ម៉ារ៉ន ជាប់ពន្ធនាគារនៅខេត្តព្រៃវែងដោយសារតែរកស៊ីគ្រឿងញៀន។ ថ្នាំញៀនខ្លួនទិញតម្លៃ ១.០០០.០០០ (មួយលាន) រៀល ខ្លួនឱ្យបានតែពាក់កណ្ដាល ហើយសន្យាថា សងលុយពាក់កណ្ដាលទៀតពេលលក់អស់។ ពីមុនមកខ្លួនប្រើប្រាស់ថ្នាំញៀនបានមកពីអ្នកក្នុងភូមិ។ រកស៊ីលក់ថ្នាំញៀនគឺប្អូនប្រុសឈ្មោះ [redacted] ម៉ារ៉ន ជាអ្នកឱ្យលេខ។ មុនពេលចាប់ខ្លួន ខ្លួនជាកសិករ មានសមាជិកគ្រួសារ ឪពុកនិងម្ដាយមានមុខរបរធ្វើស្រែចម្ការដូចគ្នា ហើយពួកគាត់មានជម្ងឺប្រចាំកាយ។ ឈ្មោះ [redacted] ម៉ារ៉ន ជាប្អូនខ្លួន ចំណែកឈ្មោះ ណាន់ ខ្លួនជាអ្នកទាក់ទងផ្ទាល់ដោយឈ្មោះ [redacted] ម៉ារ៉ន ឱ្យតែលេខឈ្មោះ ណាន់ មកខ្លួន។ ក្នុងករណីតុលាការសម្រេចផ្ដល់ស្ថានសម្រាល ខ្លួននឹងកែប្រែ។ ពេលចាប់ខ្លួនមានតែលុយ ៥០.០០០ (ប្អូនម៉ឺន) រៀល ទូរស័ព្ទមិនចាំម៉ាក ថ្នាំញៀន ចំណែកទូរស័ព្ទចំនួន ២ គ្រឿង។ ប្អូនខ្លួនឈ្មោះ [redacted] ម៉ារ៉ុម។

**សិទ្ធិនិយាយស្ដីរបស់គាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**

**ក. ការកត់សម្គាល់ខ្លីៗរបស់៖**

១. ជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ុង**៖ សូមបន្ធូរបន្ថយទោសដល់ខ្លួនផង។

២. ជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ន**៖ អវត្តមាន។

**ខ. សេចក្ដីសន្និដ្ឋាន៖**

**១. សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ៖**

ឆ្លងតាមការពិភាក្សាដេញដោលនាទីចុងក្រោយនេះ ជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ុង ឆ្លើយសារភាពអង្គហេតុដែលជនជាប់ចោទប្រព្រឹត្តបានប្រព្រឹត្តជាប្រព័ន្ធ មានអ្នកលក់ អ្នកទិញ អ្នកធ្វើការទំនាក់ទំនង អ្នកកណ្ដាលជាបុគ្គលជាប់ពន្ធនាគារខេត្តព្រៃវែង វាជាសកម្មភាពគគ្រិកគគ្រេងសកម្មណាស់ ឱ្យឈ្មោះ [redacted] ម៉ារ៉ុង នៅក្រៅឃុំបែកគំនិតទិញគ្រឿងញៀន ធ្វើតាមវីរៈប៊ុនថា ជាសកម្មភាពគគ្លើន សមត្ថកិច្ចដកហូតបានទម្ងន់ជាង ២០ក្រាម គិតជាតម្លៃ ១.០០០.០០០ (មួយលាន) រៀល ជាចំនួនច្រើនគួរឱ្យកត់សម្គាល់។ ការស៊ើបអង្កេត ការស៊ើបសួរអាចស្វែងរកអត្តសញ្ញាណអ្នកលក់ថ្នាំញៀនបាន។ តាមលិខិតចោទប្រកាន់ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន កថាខណ្ឌទី៣ កថាខណ្ឌទី៥ និងកថាខណ្ឌទី៦ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន សង្ស័យមានបរិមាណច្រើន ការស៊ើបសួរទទួលលទ្ធផលកោសលវិច័យ លទ្ធផលនៃការធ្វើតេស្ដជាប្រភេទមេតំហ្វេតាមីន បរិមាណធាតុសុទ្ធមានតែ ៣៨,៩២ ភាគរយទេ។ ឃើញថា ភាពសុទ្ធសរុប ៩,៥២ ក្រាម ហេតុនេះដីកាសន្និដ្ឋានស្ពាតរចោទ ចោទប្រកាន់តាមមាត្រា ៤០ កថាខណ្ឌទី៣ និងទី៤ ជាបទល្មើសមជ្ឈិម ចាប់ពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ តែមិនដឹងថា មានបញ្ហាបច្ចេកទេសអ្វីនោះទេ ទោះជាយ៉ាងនេះក្ដី ភស្តុតាងរឹងមាំ ការជំនុំជម្រះមានចៅក្រមច្រើនផ្ដល់នូវគុណតម្លៃពីសិទ្ធិរបស់ជនជាប់ចោទយ៉ាងល្អ។ ដូចនេះស្នើសុំប្រធានក្រុមប្រឹក្សាសម្រេចផ្ដន្ទាទោសឈ្មោះ [redacted] ម៉ារ៉ុង និងឈ្មោះ [redacted] ម៉ារ៉ន មានពិរុទ្ធភាពដូចការចោទប្រកាន់ទី១ [redacted] ម៉ារ៉ុង ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុ

ញៀន តាមមាត្រា ៤០ កថាខណ្ឌទី៣ កថាខណ្ឌទី៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បរិមាណសរុបជាបទឧក្រិដ្ឋ ករណីចរាចរណ៍មានបុគ្គលច្រើននាក់ទទួលរងគ្រោះដោយសារទិញ។ ប្អូនរបស់ជនជាប់ចោទក៏ជាប់ពន្ធនាគារដែរ នៅតែគគ្លើន តាមចរិតលក្ខណៈគួរសម្រេចជាអតិបរមា។ ទី២ ឈ្មោះ [redacted] ម៉ារ៉ន មិនផ្តល់ការអនុគ្រោះដោយសារតែខ្លួនជាប់ពន្ធនាគារ តែបែរជានាំអ្នកនៅខាងក្រៅរកស៊ីគ្រឿងញៀនទៀត។ ទាល់តែមានផលប្រយោជន៍ដល់ឈ្មោះ [redacted] ម៉ារ៉ុង ទើបស្វែងរកលេខអ្នកលក់។

**២. សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

**២.១. លោក** [redacted] ក្រោយស្តាប់ការដេញដោល ចម្លើយសារភាពរបស់កូនក្តី បានសារភាពទោសកំហុស និងដឹងខ្លួនខ្វះការពិចារណា ខ្វះការអប់រំ និងកត្តាជីវភាព កត្តាជម្រុញឱ្យប្រព្រឹត្ត ចម្លើយសារភាពថាការប្រព្រឹត្តលើកទី១ ក៏មិនទាន់ចែកចាយដែរ ស្នើសុំប្រធានក្រុមប្រឹក្សាសម្រេចផ្តន្ទាទោស និងផ្តល់ស្ថានសម្រាលទោស មាត្រា ៩៤ ចំណុច ៣ ដើម្បីឱ្យកូនក្តីខ្លួនបានមើលថែឪពុកម្តាយ និងចិញ្ចឹមបីបាច់។

**២.២. លោក** [redacted] ខ្លួនសូមឯកភាពតាមសហភាគា ជនជាប់ចោទមានឪពុកម្តាយចាស់ជរាមានជម្ងឺស្ទូត និងជម្ងឺភ្នែក។ ជនជាប់ចោទជាប់ឃុំមិនអាចរកស៊ីចិញ្ចឹមឪពុកម្តាយ ស្នើសុំផ្តល់ស្ថានសម្រាលទោស និងវិលត្រឡប់ជួបជុំគ្រួសារ ធ្វើការងារស្របច្បាប់អាចដោះស្រាយជីវភាពត្រឹមកម្រិតស្រាល។

*- ក្រោយពីបាន ស្តាប់កិច្ចពិភាក្សាដេញដោលរួចហើយ*

*- ក្រោយពីបាន ស្តាប់សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល*

## សំអាងហេតុ

### ក. អំពីសមត្ថកិច្ចនៃការជំនុំជម្រះរឿងក្តី

សាលាដំបូងខេត្តកណ្តាលបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **១៨៧៨ អ.ក** ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ុង** ភេទប្រុស អាយុ ៣១ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ មកជំនុំជម្រះពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងឈ្មោះ [redacted] **ម៉ារ៉ន** ហៅ **ញ៉ាញ់** ភេទប្រុស អាយុ ២៧ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ មកជំនុំជម្រះពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅខេត្តព្រៃវែង កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្តាលមានសមត្ថកិច្ចក្នុងការជំនុំជម្រះ៕

### ខ. អំពីដែនកំណត់នៃការប្តឹងចំពោះអង្គហេតុ និងបុគ្គល

ដែនកំណត់នៃការប្តឹងទៅតុលាការចំពោះអង្គហេតុ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្តឹងទៅតុលាការចំពោះបុគ្គល តាម



Scanned with CamScanner

មាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្ដាល មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើអង្គហេតុដែលប្ដឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ុង** និងឈ្មោះ [redacted] **ម៉ារ៉ន** ហៅ **ញ៉ាញ់**៕

**គ. អំពី ពិរុទ្ធភាព**

១. តាមចម្លើយជនជាប់ចោទក្នុងកិច្ចពិភាក្សាដេញដោលបង្ហាញថា អង្គហេតុដែលបានប្ដឹងមកតុលាការពិតជាកើតមានឡើងប្រាកដ។ តុលាការយល់ឃើញថា ការណ៍ដែលអង្គហេតុដែលប្ដឹងមកតុលាការត្រូវបានទទួលស្គាល់តុលាការនឹងបន្តផ្ទៀតផ្ទាត់ និងវាយតម្លៃរវាងបទល្មើសដែលត្រូវបានចោទប្រកាន់។

**២.** តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៤៤៨៦១/២៣ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បង្ហាញថា សារធាតុញៀនដែលបានចាប់យក និងបញ្ជូនទៅកោសលវិច័យ មានទម្ងន់សរុបស្មើនឹងចំនួន **២៤.៤៨ (ម្ភៃបួនក្បៀសសែសិបប្រាំបី) ក្រាម** ជាប្រភេទមេតំហ្វេតាមីន មានកម្រិតធាតុសុទ្ធចំនួន **៣៨.៩២ (សាមសិបប្រាំបីក្បៀសកៅសិបពីរ) ភាគរយ** នៃទម្ងន់សរុបស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ហេតុនេះ សារធាតុញៀនប្រភេទមេតំហ្វេតាមីន ដែលចាប់យកទម្ងន់សរុបស្មើនឹងចំនួន **២៤.៤៨ (ម្ភៃបួនក្បៀសសែសិបប្រាំបី) ក្រាម** មានបរិមាណសុទ្ធ ស្មើនឹងចំនួន ***២៤.៤៨ (ម្ភៃបួនក្បៀសសែសិបប្រាំបី) ក្រាម គុណនឹង ៣៨.៩២ (សាមសិបប្រាំបីក្បៀសកៅសិបពីរ) ចែកនឹង ១០០ (មួយរយ) ស្មើនឹងចំនួន ៩.៥២ (ប្រាំបួនក្បៀសហាសិបពីរ) ក្រាម។***

៣. តាមសំអាងហេតុចំណុចទី១ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ុង** បានបំពេញធាតុសត្យានុម័តនៃបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្ដាល កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ព្រោះជនជាប់ចោទបានសារភាពថា ខ្លួនបានទិញដើម្បីលក់ និងបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនពីជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ន** ហៅ **ញ៉ាញ់**។ ដោយឡែក ជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ន** ហៅ **ញ៉ាញ់** បានបំពេញធាតុសត្យានុម័តនៃបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅខេត្តព្រៃវែង កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ទី៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ព្រោះជនជាប់ចោទជាអ្នកផ្ដើមគំនិតក្នុងការទិញដើម្បីលក់ដោយខុសច្បាប់នូវសារធាតុញៀន ហើយពុំមានភស្តុតាងផ្ទុយណាមួយដែលជនជាប់ចោទអាចបដិសេធចំពោះការចោទប្រកាន់ខាងលើនេះ ព្រោះតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ុង** បានឆ្លើយយ៉ាងច្បាស់លាស់គ្រប់ដំណាក់កាលថា ខ្លួនបានលេខទូរស័ព្ទរបស់ឈ្មោះ ណាន់ ពីជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ន** ហៅ **ញ៉ាញ់** ដើម្បីទាក់ទងក្នុងការទិញសារធាតុញៀនដើម្បីលក់។

**៤.** តាមសំអាងហេតុចំណុចទី១ ដល់ចំណុចទី៣ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ុង** បានបំពេញធាតុអត្តនោម័តនៃបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រោះជនជាប់ចោទបានទិញដើម្បីលក់ និងបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ិន** ហៅ **ញ៉ាញ់** បានបំពេញធាតុអត្តនោម័តនៃបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅខេត្តព្រៃវែង កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលជាចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើសតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ដោយហេតុថា ជនជាប់ចោទមានចេតនាទុច្ចរិត ព្រោះជនជាប់ចោទបានដឹងនូវអំពើរបស់ខ្លួនថា ជាបទល្មើស និងអាចព្យាករណ៍បាននូវអំពើរបស់ខ្លួន។

**៥.** តាមសំអាងហេតុចំណុចទី១ ដល់ចំណុចទី៤ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ុង** បានបំពេញធាតុផ្សំនៃបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ិន** ហៅ **ញ៉ាញ់** បានបំពេញធាតុផ្សំនៃបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅខេត្តព្រៃវែង កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ឃ. អំពីការទទួល ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

តាមរយៈភស្តុតាងក្នុងសំណុំរឿង ពុំមានភស្តុតាងណាមួយអាចបញ្ជាក់បានថា នៅពេលកំពុងប្រព្រឹត្តបទល្មើស ជនជាប់ចោទ កើតមានវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់ដឹងខុសត្រូវរបស់ខ្លួន បន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ តាមមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះ ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត តាមមាត្រា ២៤ និងមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ។

**ង. អំពី ការប្រកាសអំពីពិរុទ្ធភាព**

តាមសំអាងហេតុចំណុច គ (អំពី ពិរុទ្ធភាព) និងចំណុច ឃ (អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ) ខាងលើ បង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ុង** បានបំពេញធាតុផ្សំនៃបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០

កថាខណ្ឌទី៣ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងឈ្មោះ [redacted] **ម៉ារិន** ហៅ **ញ៉ាញ់** បានបំពេញធាតុផ្សំនៃបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅខេត្តព្រៃវែង កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ុង** មានពិរុទ្ធភាពពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងជនជាប់ចោទឈ្មោះ [redacted] **ម៉ារិន** ហៅ **ញ៉ាញ់** មានពិរុទ្ធភាពពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅខេត្តព្រៃវែង កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន៕

**ច. អំពីការពិចារណាលើស្ថានសម្រាល និងស្ថានទម្ងន់ទោស**

អំពើរបស់ជនជាប់ចោទ មិនបានបង្កើតឱ្យមានស្ថានទម្ងន់ទោសណាមួយចំពោះជនជាប់ចោទ តាមមាត្រា ៨៣ ដល់មាត្រា ៩២ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការនឹងសម្រេចពុំពិចារណាអំពីស្ថានទម្ងន់ទោសនោះទេ។ ចំពោះ ស្ថានសម្រាលទោស តាមមាត្រា ៩៤ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ពុំមានភស្តុតាង ឬសញ្ញាណណាមួយដែលអាចបង្ហាញបានថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ ហេតុដូច្នេះ នឹងសម្រេចពុំពិចារណាអំពីស្ថានសម្រាលទោសនោះទេ៕

**ឆ. អំពីរបបនៃការប្រកាសទោស**

**ឆ.១. ការប្រកាសអំពីមូលទោស**

តាមកាលៈទេសៈនៃបទល្មើស តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តាមសភាពផ្លូវចិត្ត តាមធនធាន និងបន្ទុក តាមមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស តុលាការនឹងសម្រេចប្រកាសមូលទោស ក្នុងទម្រង់ជាការប្រកាសទោសដាក់ពន្ធនាគារ តាមមាត្រា ២៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយសម្រេចប្រកាសទោសដាក់ពន្ធនាគារលើជនជាប់ចោទ៖

១. ឈ្មោះ [redacted] **ម៉ារ៉ុង** ភេទប្រុស អាយុ ៣១ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ ចំនួន **៤ (បួន) ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **៨.០០០.០០០ (ប្រាំបីលាន) រៀល** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយផ្អែកទៅលើសារធាតុសុទ្ធនៃសារធាតុញៀនដែលចាប់យកបាន និងទៅលើកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស និងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស ដែលសហការសារភាពចំពោះអំពើរបស់ខ្លួន។



Scanned with CamScanner

**២.** ឈ្មោះ [redacted] **ម៉ាវិន** ហៅ **ញ៉ាញ់** ភេទប្រុស អាយុ ២៧ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ ចំនួន **៤ (បួន) ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **៨.០០០.០០០ (ប្រាំបីលាន) រៀល** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅខេត្តព្រៃវែង កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដោយផ្អែកទៅលើសារធាតុសុទ្ធនៃសារធាតុញៀនដែលចាប់យកបាន និងដោយផ្អែកទៅលើកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស។

**គ.២. ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត**

ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត តុលាការនឹងមិនលើកយកមកពិចារណានោះទេ។

**ជ. អំពី សេចក្តីសម្រេចពិសេសលើការបង្គាប់ឱ្យចាប់ខ្លួន ឬការបង្គាប់ឱ្យឃុំខ្លួន**

ដោយផ្អែកតាមភស្តុតាង និងតាមរយៈកិច្ចពិភាក្សាដេញដោលក្នុងសវនាការ បង្ហាញថា តាមកាលៈទេសៈនៃបទល្មើស តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តាមសភាពផ្លូវចិត្ត តាមធនធាននិងបន្ទុក តាមមូលហេតុព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស តុលាការសម្រេចឱ្យចាប់ខ្លួនឈ្មោះ [redacted] **ម៉ាវិន** ហៅ **ញ៉ាញ់** ភេទប្រុស អាយុ ២៧ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ។

**ឈ. អំពី វត្ថុចាប់យក**

វត្ថុចាប់យករួមមាន សារធាតុញៀនប្រភេទមេតំហ្វេតាមីន ទម្ងន់ ២៤.៤៨ (ម្ភៃបួនក្បៀសសែសិបប្រាំបី) ក្រាម ទូរស័ព្ទដៃចំនួន ២ គ្រឿងម៉ាក HUAWIE និង NOKIA ខោជើងវែង ១ និងថង់វេចខ្ចប់របស់ក្រុមហ៊ុន គឺជាវត្ថុដែលជាកម្មវត្ថុនៃបទល្មើស ហេតុដូច្នេះ តុលាការសម្រេចរឹបអូសវត្ថុចាប់យកទាំងអស់ដែលបានចាប់យក តាមមាត្រា ៩៣ មាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**សេចក្តីសម្រេច**

**ក. ប្រកាសថា មានពិរុទ្ធភាពលើជនជាប់ចោទ៖**

១. ឈ្មោះ [redacted] **ម៉ារ៉ុង** ភេទប្រុស អាយុ ៣១ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២.** ឈ្មោះ [redacted] **ម៉ាវិន** ហៅ **ញ៉ាញ់** ភេទប្រុស អាយុ ២៧ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅខេត្តព្រៃវែង កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ខ. ផ្តន្ទាទោសជាទោសដាក់ពន្ធនាគារលើជនជាប់ចោទ៖**

១. ឈ្មោះ [redacted] **ម៉ារ៉ុង** ភេទប្រុស អាយុ ៣១ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ ចំនួន **៤ (បួន) ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **៨.០០០.០០០ (ប្រាំបីលាន) រៀល** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្ត



Scanned with CamScanner

កណ្តាល កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ខ.** ឈ្មោះ [redacted] **ម៉ារីន** ហៅ **ញ៉ាញ់** ភេទប្រុស អាយុ ២៧ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ ចំនួន **៤ (បួន) ឆ្នាំ** និងពិន័យជាប្រាក់ចំនួន ៨.០០០.០០០ **(ប្រាំបីលាន) រៀល** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅខេត្តព្រៃវែង កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**គ.** បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] **ម៉ារីន** ហៅ **ញ៉ាញ់** ភេទប្រុស អាយុ ២៧ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ឃ.** វត្ថុចាប់យករួមមាន សារធាតុញៀនប្រភេទមេតំហ្វេតាមីនទម្ងន់ ២៤.៤៨ (ម្ភៃបួនក្បៀសសែសិបប្រាំបី) ក្រាម ទូរស័ព្ទដៃចំនួន ២ គ្រឿងម៉ាក HUAWIE និង NOKIA ខោជើងវែង ១ និងថង់វេចខ្ចប់របស់ក្រុមហ៊ុន ត្រូវរឹបអូស។

*សំណុំរឿងព្រហ្មទណ្ឌនេះជំនុំជម្រះជាសាធារណៈនៅចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ុង កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ម៉ារីន។*

*សាលក្រមព្រហ្មទណ្ឌនេះប្រកាសជាសាធារណៈនៅថ្ងៃ ពុធ ៧ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង ១១ ព្រឹក នៅសាលសវនាការលេខ ៤។*

*ភាគីដែលមានបំណងធ្វើបណ្តឹងទាស់ ឬបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះ ត្រូវធ្វើបណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍នេះ តាមការកំណត់របស់ច្បាប់។*

**ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម**

| ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ពុធ ៧ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤

| បានឃើញ | |
|---|---|
| ប្រធានក្រុមប្រឹក្សាជំនុំជម្រះ | ក្រឡាបញ្ជីសវនាការ |
| [redacted] | [redacted] |